# សុន្ទរកថារបស់ លោក BESSHO Kenichi ឧបទូតនៃស្ថានទូតជប៉ុនប្រចាំកម្ពុជា
# ថ្លែងក្នុងពិធីសម្ពោធដាក់អោយប្រើប្រាស់ជាផ្លូវការនូវអគារសិក្សា៦បន្ទប់
# នៅវិទ្យាល័យស្លាបលែង ក្នុងស្រុកបសេដ្ឋ ខេត្តកំពង់ស្ពឺ

- សូមក្រាបថ្វាយបង្គំ ព្រះសង្ឃ គ្រប់ព្រះអង្គ
- សូមគោរព ឯកឧត្តម ហ៊ុន ម៉ានី សមាជិកសភា
- សូមគោរព ឯកឧត្តម វ៉ី សំណាង អភិបាលខេត្តកំពង់ស្ពឺ
- សូមគោរព ភ្ញៀវកិត្តិយសទាំងអស់

ថ្ងៃនេះ ខ្ញុំសប្បាយរីករាយណាស់ ដែលបានចូលរួមអបអរសាទរក្នុងពិធីសម្ពោធអគារសិក្សាថ្មី នៅសាលាស្លាបលែង ដោយមានវត្តមានរបស់ឯកឧត្តម ហ៊ុន ម៉ានី ឯកឧត្តម វ៉ី សំណាង និងភាគីពាក់ព័ន្ធទាំងអស់។ ខ្ញុំសូមសម្តែងចំណាប់អារម្មណ៍តំណាងឲ្យស្ថានទូតជប៉ុននៅកម្ពុជា។

ការអប់រំកុមារ គឺជាកត្តាសំខាន់ សម្រាប់អនាគតរបស់កម្ពុជា។ រដ្ឋាភិបាលជប៉ុន គាំទ្រវិស័យអប់រំនៅកម្ពុជា តាមគម្រោងគូសាណូណិផងដែរ។

អគារសិក្សានេះ ត្រូវបានសាងសង់ តាមរយៈជំនួយគូសាណូណិ។ នេះ គឺជាគម្រោងទី16 និងជាសាលាទី39 ដែលត្រូវបានសាងសង់ ក្នុងខេត្តកំពង់ស្ពឺ។ ក្នុងគម្រោងនេះ រដ្ឋាភិបាលជប៉ុន បានផ្តល់ជូននូវអគារសិក្សា 6បន្ទប់ បន្ទប់ទឹក 2 និងបរិក្ខារសិក្សា ដូចជា៖ តុ កៅអី ជាដើម។ ខ្ញុំសប្បាយរីករាយណាស់ ដែលសិស្សច្រើនជាង 1,100 នាក់ អាចសិក្សាបានដោយសុវត្ថិភាព។

តំណាងឲ្យរដ្ឋាភិបាលជប៉ុន ខ្ញុំសង្ឃឹមថា ជំនួយនេះ នឹងត្រូវបានថែទាំយ៉ាងល្អ និងប្រើប្រាស់ឲ្យបានយូរអង្វែង ហើយនឹងក្លាយជានិមិត្តរូបនៃមិត្តភាពរវាងកម្ពុជា និងជប៉ុន។

ជាទីបញ្ចប់ ខ្ញុំសូមអរគុណជាថ្មីម្តងទៀត ដល់មន្ទីរ អប់រំ ខេត្តកំពង់ស្ពឺ និងលោក-អ្នកទាំងអស់ ដែលបានអនុវត្តគម្រោងនេះ។ ខ្ញុំ ក៏សូមជូនពរឲ្យមិត្តភាពរវាងកម្ពុជា និងជប៉ុន មានការរីកចម្រើនមួយកម្រិតទៀត៕

**សូមអរគុណ!**